## ការសួរតទល់ (cross-examination)

ការសួរតទល់ ជាមូលដ្ឋានគ្រឹះនៃប្រព័ន្ធតទល់ (adversary system) ដែលជាការសួរសាក្សីដោយភាគីដទៃ (direct examination/examination in chief)។ សំណួរលើកឡើង ត្រូវពាក់ព័ន្ធជាមួយនឹងបញ្ហា ត្រូវបានលើកឡើង ហើយភាគីអាចប្រើសំណួរដឹកមុខ (leading questions)។ វាជានីតិវិធី ដើម្បីតវ៉ានឹងភស្តុតាង (evidence)។

ការសួរតទល់ បានក្លាយជាសិទ្ធិមនុស្សចម្បងមួយ (Prlic, IT-04-74-AR73.2, 2006)។ វាទាមទារឲ្យគោរពវិធានមួយចំនួន ដូចជា ការហាមឃាត់ការវាយប្រហារសាក្សី ដោយគ្មានមូលដ្ឋានសមហេតុផល សម្រាប់ការធ្វើដូចនេះ។ ឧទាហរណ៍ គេមិនអាចនិយាយពីប្រវត្តិជាប់ទោសរបស់សាក្សី ដោយគ្មានផ្តល់ព័ត៌មាន អំពីការចោទប្រកាន់ដោយសុទ្ធចិត្ត (good faith) នោះទេ។

ចៅក្រមមានឆន្ទានុសិទ្ធិទូលាយ ក្នុងការកម្រិតវិសាល និង រយៈពេលនៃការសួរដេញដោល (Antonio Cassese, the Oxford Companion to International Criminal Justice, 2009,p. 228).